**ជោគជ័យ ហ្វាយនែន**

ជម្រើសប្រសើរបំផុតដើម្បីជោគជ័យ

# របាយការណ៍ប្រចាំឆ្នាំ

# ២០២២

# ប្រវត្តិសង្ខេបរបស់ ជោគជ័យ ហ្វាយនែន

## (2016 - 2022) រយៈពេល 07 ឆ្នាំនៃប្រតិបត្តិការ

| 02ឆ្នាំ គ្រប់គ្រងដោយ វិនិយោគទុនក្នុងស្រុក | | 05ឆ្នាំ គ្រប់គ្រងដោយ វិនិយោគទុនកូរ៉េ | | | | |
|---|---|---|---|---|---|---|
| **2016** | **2017** | **2018** | **2019** | **2020** | **2021** | **2022** |
| ទទួលបានអាជ្ញាបណ្ណប្រកបអាជីវកម្មជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពី ធនាគារជាតិនៃកម្ពុជា | ត្រូវបានទិញដោយក្រុមហ៊ុនកូរ៉េ 2 គឺ<br>- **Hanshin E&C**<br>- **Plus International** | បើកសម្ពោធសាខាថ្មីចំនួន 5 គឺ :<br>- សាខាទួលគោក<br>- សាខាតាខ្មៅ<br>- សាខាថ្នល់ទទឹង<br>- សាខាកំពង់ស្ពឺ<br>- សាខាជើងព្រៃ | ដាក់ឲ្យប្រើប្រាស់ប្រព័ន្ធធនាគារស្នូលថ្មីរបស់កូរ៉េ ឈ្មោះថា “**Apsara** ” | • ដាក់ឲ្យប្រើប្រាស់នូវស្លាកសញ្ញាថ្មី<br>• បើកសម្ពោធសាខាថ្មីចំនួន 2 គឺ:<br>- សាខាគងពិសី<br>- សាខាកំពង់ត្រឡាច | បើកសម្ពោធសាខាថ្មីចំនួន 1 គឺ:<br>- សាខាត្រាំកក់ | បើកសម្ពោធសាខាថ្មីចំនួន 2 គឺ:<br>- សាខាឈូក<br>- សាខាស្រីសន្ធរ |










# ទិន្នន័យសំខាន់ៗអំពី ជោគជ័យ

( គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ2022 )

**សមតុល្យផលបត្រឥណទាន**
52,0 លាន ដុល្លារ

**ប្រាក់ចំណេញសុទ្ធ**
1,3 លាន ដុល្លារ

**ដើមទុនចុះបញ្ជី**
5,5 លាន ដុល្លារ

**ផលលើមូលធន**
16.3%

**មូលនិធិផ្ទាល់សុទ្ធ**
10,7 លាន ដុល្លារ

**ផលលើទ្រព្យសកម្ម**
2.5%

**អត្រាឥណទានមិនដំណើរការ**
1.5%

**ចំនួនសាខាប្រតិបត្តិការ**
11

# មាតិកា

### ទិដ្ឋភាពទូទៅ


- ប្រវត្តិសង្ខេបរបស់ ជោគជ័យ ហ្វាយនែន ........ 1
- ទិន្នន័យសំខាន់ៗអំពី ជោគជ័យ ........ 2
- ភាគទុនិក ........ 5
- រចនាសម្ព័ន្ធស្ថាប័ន ........ 7
- រចនាសម្ព័ន្ធប្រតិបត្តិការគោល ........ 9


### អំពីជោគជ័យ


- ចក្ខុវិស័យ និង បេសកកម្ម ........ 11
- វប្បធម៌នៃភាពជោគជ័យ ........ 13
- ក្រុមប្រឹក្សាភិបាល ........ 27
- គណៈគ្រប់គ្រង ........ 28


### ទិដ្ឋភាពទូទៅនៃអាជីវកម្ម


- ដៃគូផ្តល់ទុនវិនិយោគ ........ 36
- ដៃគូអាជីវកម្ម ........ 36
- សមាជិកភាព ........ 36
- ការបង្ហាញទិន្នន័យត្រួសៗ ........ 37
- ផលិតផលឥណទាន ........ 39
- សាខាប្រតិបត្តិការ ........ 40
- ប្រវត្តិជោគជ័យរបស់អតិថិជន ........ 41


### របាយការណ៍ហិរញ្ញវត្ថុ


- របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ........ 44
- របាយការណ៍របស់សវនករឯករាជ្យ ........ 49
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ........ 52
- របាយការណ៍លទ្ធផលលម្អិត ........ 54
- របាយការណ៍ស្ដីពីបម្រែបម្រួលមូលធន ........ 55
- របាយការណ៍លំហូរសាច់ប្រាក់ ........ 57

# ភាគទុនិក




## ក្រុមហ៊ុន Hanshin E&C

ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ 1950 ដោយជាក្រុមហ៊ុនសាងសង់លំនៅឋាន ហើយក៏បានបន្តទៅផ្នែកស្ថាប័ត្យកម្ម ការងារស៊ីវិល អគ្គិសនី និង ជំនួញដាំដុះផ្សេងៗ។ ក្រុមហ៊ុនក៏បានបន្តលូតលាស់ទៅជាក្រុមហ៊ុនសាងសង់ទូទៅ ដែលលេចធ្លោបំផុតមួយនៅក្នុងប្រទេសកូរ៉េ។

Hanshin មានមោទនភាពមិនត្រឹមតែបានចូលរួមចំណែក ទៅលើការអភិវឌ្ឍន៍នៃការសាងសង់ផ្ទះសំបែងចំនួន 28ម៉ឺនផ្ទះប៉ុណ្ណោះទេ តែថែមទាំងដើរតួយ៉ាងសំខាន់ក្នុងការសាងសង់ ហេដ្ឋារចនាសម្ព័ន្ធជាតិ តាមរយៈការសាងសង់ផ្លូវហាយវ៉េ ផ្លូវថ្នល់ទូទៅ ផ្លូវក្រោមដី ផ្លូវដែកដែលមានល្បឿនលឿន និង ការងារជាច្រើនទៀត លើការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក សំរាប់រយៈពេលកន្លះសតវត្សកន្លងទៅនេះផងដែរ។

Hanshin ក៏ថែមទាំងបានជំរុញកេរ្តិ៍ឈ្មោះ និង កិត្តិយសជាតិ តាមរយៈការសាងសង់យ៉ាងសកម្មនៅក្រៅប្រទេស ដូចជា នៅក្នុងប្រទេស អារ៉ាប់ គុយវ៉ែត និង ចិន ចាប់តាំងពីឆ្នាំ 1970។

ថ្មីៗនេះ Hanshin ក៏ថែមទាំងទទួលបានកេរ្តិ៍ឈ្មោះជាអន្តរជាតិ ទៅលើបច្ចេកវិទ្យា និង សមត្ថភាពសាងសង់ដែលទាន់សម័យរបស់ខ្លួនផងដែរ ដោយបាន



ក្រុមហ៊ុន Hanshin E&C Co.,ltd
( ទីស្នាក់ការកណ្តាលស្ថិតនៅ ទីក្រុងសេអ៊ូល ប្រទេសកូរ៉េ )

ចូលរួមទៅលើជំនួញនានាដែលស្ថិតនៅក្នុងប្រទេសវៀតណាម និង បណ្តាប្រទេសអាស៊ីអាគ្នេយ៍ជាច្រើនទៀត ដូចជា ប្រទេសហ្វីលីពីន ភូមា កម្ពុជា ។ល។

ដើម្បីក្លាយជាក្រុមហ៊ុនសាងសង់កម្រិតកំពូល ថ្នាក់ពិភពលោកនៅក្នុងយុគសម័យជាសកលនេះ Hanshin និង បុគ្គលិកទាំងអស់កំពុងតែប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការពង្រឹងសមត្ថភាពប្រកួតប្រជែងជាសកល ដើម្បីឲ្យក្តីស្រមៃ និង ការសង្ឃឹមរបស់អ្នកក្លាយជាការពិត។ Hanshin សន្យាថានឹងផ្តល់នូវមជ្ឈដ្ឋានរស់នៅដែលរីករាយ និង មានផាសុកភាព ជាមួយនឹងបច្ចេកវិទ្យាសាងសង់ដែលទាន់សម័យ និង គុណភាពចំណាត់ថ្នាក់ទី1។



## គម្រោងសាងសង់របស់ក្រុមហ៊ុន Hanshin E&C



- អាគារ Sultan
- ផ្ទះល្វែង Yanjil Hanshin
- ផ្លូវហាយវេ Mongolia Millenium
- អគារ Kuwait Religious Complex
- អគារ Jubail Royal Committee Housing Corporation
- អគារ Hanoi HH4 Mixed-use Complex (ការរចនា/ការត្រួតពិនិត្យ) ។ល។
- ផ្លូវជាតិលេខ 2, 21 និង 5 នៅក្នុងប្រទេសកម្ពុជា ។ល។





## ក្រុមហ៊ុន Plus International

មានមូលដ្ឋាននៅប្រទេសកូរ៉េខាងត្បូង ដែលការិយាល័យកណ្តាលនៅក្នុងទីក្រុង សេអ៊ូល។ ក្រុមហ៊ុនប្រតិបត្តិការទៅលើវិស័យអចលនទ្រព្យ ហើយត្រូវបានបង្កើតឡើងនៅថ្ងៃទី 4 មេសា ឆ្នាំ2011។

**លក្ខណៈជំនួញ៖**

- ដំណើរការគម្រោងអភិវឌ្ឍអចលនទ្រព្យ
- សហការជាមួយ Hanshin ដើម្បីបង្កើតជំនួញថ្មី
- វិនិយោគ និង ធ្វើការជាមួយ M&A នៅក្នុងប្រទេស និង នៅបរទេស
- ស្វែងរក និង ដឹកនាំជំនួញនៅក្នុងប្រទេសកម្ពុជា និង វៀតណាម



ក្រុមហ៊ុន Plus International

# រចនាសម្ព័ន្ធស្ថាប័ន



# រចនាសម្ព័ន្ធប្រតិបត្តិការគោល

សាខាទាំងអស់ត្រូវបានគ្រប់គ្រងយ៉ាងម៉ត់ចត់ដោយ
ការិយាល័យកណ្តាល ដើម្បីការរីកលូតលាស់ដែលមាន
ការយកចិត្តទុកដាក់ និង ស្ថេរភាព




# អំពីជោគជ័យ


ចក្ខុវិស័យ និង បេសកកម្ម .......... 11
វប្បធម៌នៃភាពជោគជ័យ .......... 13
ក្រុមប្រឹក្សាភិបាល .......... 27
គណៈគ្រប់គ្រង .......... 28



## ចក្ខុវិស័យ

យើងខិតខំប្រឹងប្រែងដើម្បីក្លាយជាក្រុមហ៊ុនហិរញ្ញវត្ថុលំដាប់ពិភពលោក “ វិសាលភាពលុបលើវិស័យធនាគារ ” ទាំងលើទំហំផលចំណេញ និង “ការទទួលស្គាល់លើកិត្យានុភាព ” (ភាពជឿជាក់ ភាពងាយស្រួល និង ល្បឿននៃសេវាកម្ម) និង “ ការបំពេញចិត្ត ដល់បុគ្គលិកគ្រប់ជាន់ថ្នាក់ ”។

## បេសកកម្ម

ទទួលបាននូវភក្តីភាពយូរអង្វែងពីសំណាក់អតិថិជន គោលដៅស្ថិតក្នុងជីវភាពទាប និង មធ្យមតាមរយៈការផ្តល់កម្ចី និង សេវាកម្មហិរញ្ញវត្ថុ ដើម្បីជួយលើកកម្ពស់ អាជីវកម្មប្រកបដោយនិរន្តរភាព ព្រមទាំងរួមចំណែកបង្កើតនូវ “វប្បធម៌នៃទម្លាប់ជោគជ័យ” សម្រាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។

## វប្បធម៌

ជា ស្ថាប័នប្រកបដោយសក្តានុពល យើងមានចក្ខុវិស័យរួមជាសកលដើម្បីប្រែក្លាយជាក្រុមហ៊ុនលំដាប់ថ្នាក់ពិភពលោក ដោយឈរលើមូលដ្ឋាន "ទម្លាប់នៃការបង្កើតភាពជោគជ័យ" និង ការអភិវឌ្ឍន៍សម្រាប់ "ការផ្លាស់ប្តូរវិជ្ជមាន"។ យើងទាំងអស់គ្នាប្រឹងប្រែងដើម្បីការរីកចម្រើនរួមគ្នា និង សម្រាប់ជីវិតឯកជនរបស់យើង។ យើងទាំងអស់គ្នាគឺគ្រួសារ ជោគជ័យ ហ្វាយនែន។

## ទស្សនៈវិស័យ

- ការផ្តល់តម្លៃបុគ្គលិកជាធំ
- ភាពស្មោះត្រង់
- ចេះទទួលយកវប្បធម៌ការងារល្អ
- ការគោរពតួនាទីរៀងៗខ្លួន
- អព្យាក្រឹត្យភាព

# វប្បធម៌នៃភាពជោគជ័យ

## ការរួមបញ្ចូលគ្នានៃ
## សកលភាវូបនីយកម្ម និង មូលដ្ឋានីយកម្ម

( សកលភាវូបនីយកម្ម + មូលដ្ឋានីយកម្ម )

## នៅក្នុងវិស័យហិរញ្ញវត្ថុ

# 1 ឈ្មោះក្រុមហ៊ុនក្នុងស្រុក

*អ្នកដឹកនាំដែលមានផ្នត់គំនិតជាសកល*

ជោគជ័យត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ2016 ដោយម្ចាស់ភាគហ៊ុនជនជាតិខ្មែរ តែយ៉ាងណាក៏ដោយឈ្មោះអាជីវកម្មមិនត្រូវបានផ្លាស់ប្តូរទៅជា Hanshin ក្នុងការធ្វើមូលដ្ឋានីយកម្មឡើយ។ ចំណុចនេះត្រូវបានផ្តល់អនុសាសន៍យ៉ាងមុតមាំពីសំណាក់លោកប្រធានក្រុមប្រឹក្សាភិបាល Moon Kyu Choi ជាមួយនឹងផ្នត់គំនិតជាសកលរបស់គាត់។ នេះក៏ដោយសារតែឈ្មោះដ៏ល្បីល្បាញរបស់ Hanshin (ដែលជាម្ចាស់ភាគហ៊ុនធំរបស់ជោគជ័យ) គឺពុំងាយនឹងត្រូវបានទទួលស្គាល់ពីសំណាក់អតិថិជនក្នុងស្រុក។ ជោគជ័យមានអត្ថន័យថា " ជោគជ័យ " ជាភាសាខ្មែរ។

ជោគជ័យ
ហ្វាយនែន

CHOKCHEY
Finance



# 2 ការធ្វើមូលដ្ឋានីកម្មដែលជោគជ័យ

## *ការសម្រេចចិត្តដោយគណៈកម្មការដែលជាគណៈគ្រប់គ្រងក្នុងស្រុក*

នៅជោគជ័យមានតែជនជាតិកូរ៉េម្នាក់ប៉ុណ្ណោះ គឺលោក Cheon Gil Park ដែលជាអគ្គនាយក។ គាត់មានជំនឿយ៉ាងមុតមាំថា មានតែអ្នកនៅក្នុងស្រុកទេដែលយល់ពីការអនុវត្តក្នុងស្រុកប្រសើរជាងជនបរទេស។ ដូច្នេះហើយ គាត់បានបើកចិត្តទូលាយក្នុងការពិភាក្សា និង ដេញដោលទៅវិញទៅមកដើម្បីរកបានដំណោះស្រាយដែលល្អប្រសើរ។






# 3 បុគ្គលិក បុគ្គលិក និង បុគ្គលិក

## *វប្បធម៌នៃការរៀនសូត្រ*

បុគ្គលិក គឺជាធនធានដ៏មានតម្លៃបំផុតសម្រាប់ជោគជ័យ។ ពួកយើងពិតជាត្រូវការស្វែងរកអ្នកដែលមានសក្តានុពលហើយបង្ហាត់បង្រៀនពួកគាត់ឲ្យក្លាយជាអ្នកដឹកនាំបែបសកលតាមរយៈកម្មវិធីបង្ហាត់បង្រៀនទៅតាមកម្រិតនៃបុគ្គលិក។










# 4 ផ្នត់គំនិតជាសកល

## *ការចាប់យកនូវបរិបទថ្មីៗជាបន្តបន្ទាប់*

យើងជឿជាក់ថា វិស័យហិរញ្ញវត្ថុគឺជាជំនួញបច្ចេកវិទ្យា។ បច្ចេកវិទ្យាវិស័យហិរញ្ញវត្ថុផ្សេងៗ ដូចជាសេវាកម្មធនាគារ និង ការទូទាត់ប្រាក់ដែលមានភាពងាយស្រួលតាមរយៈទូរស័ព្ទដៃបានកំពុងចូលមកជំនួសឲ្យវិធីសាស្រ្តបែបបុរាណនៃសេវាកម្មធនាគារ។ ដូច្នេះហើយយើងត្រូវតែចាប់ឲ្យទាន់នូវនិន្នាការថ្មីៗ តាមរយៈការចូលរួមពិព័រណ៍បច្ចេកវិទ្យាវិស័យហិរញ្ញវត្ថុនៅសិង្ហបុរី ក៏ដូចជាការធ្វើដំណើរទៅប្រទេសកូរ៉េ ដើម្បីទទួលបានបទពិសោធន៍កម្មវិធីបច្ចេកវិទ្យាវិស័យហិរញ្ញវត្ថុដែលអស្ចារ្យជាច្រើន រួមទាំងវប្បធម៌ថ្មីៗផងដែរ។


1



2


3


4

1 & 2. ការធ្វើដំណើរទៅប្រទេសកូរ៉េ
3 & 4. ពិព័រណ៍បច្ចេកវិទ្យាវិស័យហិរញ្ញវត្ថុនៅសិង្ហបុរី

# 5 ការទំនើបកម្មទៅជាបែបឌីជីថលនៅក្នុងប្រតិបត្តិការការងារ

## *ការទំនាក់ទំនងដែលទូលំទូលាយ*



យើងប្រើប្រាស់កម្មវិធី Microsoft Teams សម្រាប់ទំនាក់ទំនងប្រតិបត្តិការការងារប្រចាំថ្ងៃ។ ការផ្តល់មតិ និង គំនិតយោបល់ គឺត្រូវបានស្វាគមន៍យ៉ាងខ្លាំង ដើម្បីទទួលបានការសម្រេចចិត្តដែលល្អប្រសើរ។ ទំនាក់ទំនងក្នុងទម្រង់ជាការសរសេរបែបអនឡាញនេះ ពិតជាអាច កាត់បន្ថយពេលវេលាក្នុងការជួបដោយផ្ទាល់។

កម្មវិធី មន្រ្តីឥណទាន CO App ដែលបានបង្កើតឡើងដោយផ្ទាល់ គឺត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធិភាព សម្រាប់ការអនុម័ត និង គ្រប់គ្រងឥណទាន។



# 6 រចនាបទរបស់ជោគជ័យ

## *ភាពជឿជាក់បានមកពីរូបសម្បត្តិដែលស្រស់ស្អាត*

ពណ៌អត្តសញ្ញាណរបស់ ជោគជ័យ គឺមានឈ្មោះថា " ពណ៌ខៀវជោគជ័យ " ដែលមានគំរូពណ៌មកពីប្រអប់ពណ៌ខៀវ Tiffany។ ឯកសណ្ឋានថ្មែម៉ូតយ៉ាងល្អ ត្រូវបានផ្តល់ទៅឲ្យបុគ្គលិកទាំងអស់ ហើយផ្ទៃខាងមុខនៃអគារសាខាក៏មានការបង្ហាញពីការកំណត់អត្តសញ្ញាណដែលខុសប្លែកមិនច្រឡំគេ ដើម្បីទាក់ទាញការចាប់អារម្មណ៍ទៅលើស្លាកសញ្ញាអាជីវកម្មពីសំណាក់អតិថិជនក្នុងស្រុក តាមរយៈចំណង់ចំណូលចិត្តនៃពណ៌របស់ពួកគេ។



ឯកសណ្ឋានការងារ



មួកសុវត្ថិភាព



កាបូបស្ពាយ



សម្ភារៈផ្សព្វផ្សាយស្លាកសញ្ញា



អាវក្រៅសម្រាប់បុគ្គលិក





ស្លាកសញ្ញាសាខា

# 7 ការរំលាយបញ្ចូលគ្នា - ការចាប់យកវប្បធម៌ចម្រុះជាតិសាសន៍

## *ដើម្បីលាយបញ្ចូលគ្នានូវចំណុចខ្លាំងនៃវប្បធម៌នីមួយៗ*

វប្បធម៌ជនជាតិខ្មែរគឺត្រូវបានគេស្គាល់តាមរយៈអាកប្បកិរិយាទន់ភ្លន់ជាមួយនឹងស្នាមញញឹម ដែលចំណែកឯជនជាតិកូរ៉េវិញ ពុំសូវញញឹមរីករាយនោះទេ ដោយមានភាពម៉ឺងម៉ាត់ និង ម៉ត់ចត់។ ក្នុងនាមជាទីក្រុងដែលមានចម្រុះជាតិសាសន៍ ប្រជាជនគួរតែរៀនបន្ថែមពីវប្បធម៌បរទេស ដោយចូលរួមកម្មវិធីផ្សេងៗ ដូចជា EuroCham AmCham និង IBC ដើម្បីទទួលបានអ្វីៗដែលថ្មី ដូចជា ច្បាប់ និង និន្នាការផ្សេងៗ ដោយការយល់ដឹង និងទទួលយកនូវវប្បធម៌ផ្សេងៗ នេះគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការបង្កើនទំនាក់ទំនងដែលល្អ និងបន្តភាពរីកចម្រើននៃអាជីវកម្ម។















1. ការធ្វើបទបង្ហាញអំពីជោគជ័យនៅឯកម្មវិធីរបស់ IBC
2 & 7. និន្នាការជំនួញដែលចែករំលែកដោយ CBRE Cambodia
3. ការជួបជុំអាហារពេលល្ងាចសម្រាប់អគ្គនាយកនៅក្នុងកម្មវិធីរបស់ EuroCham
4. កម្មវិធីរបស់ AmCham
5. កម្មវិធីសមាគមន៍សហគ្រិនវ័យក្មេងកម្ពុជា
6. ការពិភាក្សាជាមួយ ID Capital









# 8 វិន័យផ្លូវច្បាប់

## *វិញ្ញាបនបត្រសារពើពន្ធប្រភេទ " **មាស** " ពីអគ្គនាយកដ្ឋានពន្ធដារ*


ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

TCG2022060007
លេខ ១៣២៤៣

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២២
Phnom Penh, 16th, June 2022

អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

វិញ្ញាបនបត្រ
អនុលោមភាពសារពើពន្ធ
(ប្រកាសលេខ ១៥៣៦ សហវ.ប្រក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦)

អគ្គនាយកដ្ឋានពន្ធដារបញ្ជាក់ថា ៖
ឈ្មោះក្រុមហ៊ុន ៖ ចោគជ័យ ហ្វាយនែន ភីអិលស៊ី
លេខអត្តសញ្ញាណកម្មសារពើពន្ធ ៖ L001-901636771
ស្ថិតក្រោមការគ្រប់គ្រង ៖ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ កាលបរិច្ឆេទធ្វើបច្ចុប្បន្នភាព ៖ ២៦ មេសា ២០១៦
សកម្មភាពអាជីវកម្ម ៖ សេវាមីក្រូហិរញ្ញវត្ថុ (ផ្តល់កម្ចី ទទួលបញ្ញើ និងផ្ទេរប្រាក់)
អាសយដ្ឋាន ៖ #៩-១១ ផ្លូវ វេងស្រេង សង្កាត់ ស្ទឹងមានជ័យ ខណ្ឌ មានជ័យ រាជធានីភ្នំពេញ
ទទួលបានកម្រិតអនុលោមភាពសារពើពន្ធប្រភេទ ៖ មាស
មានសុពលភាពរយៈពេល ២ ឆ្នាំ សម្រាប់ឆ្នាំជាប់ពន្ធ ២០២២ ដល់ ឆ្នាំ២០២៣។

CERTIFICATE OF TAX COMPLIANCE
(Prakas No 1536 MEF/PK dated 23rd December 2016)

GENERAL DEPARTMENT OF TAXATION certifies that :
Company's name : CHOKCHEY FINANCE PLC.
Tax Identification Number (TIN) : L001-901636771
Under : Department of large Taxpayers Date of Information Update : 26 Apr 2016
Business activity(ies) : Microfinance services (loan, depository and money transfer)
Tax Compliance Type awarded : GOLD
Validity period of 2 years for the tax year of 2022 and 2023.

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ
Minister Attached to the Prime Minister
Delegate of Royal Government
In Charge as Director General of the General Department of Taxation
គង់ វិបុល

# 9 ភាពស្មោះត្រង់ គឺជាគោលការណ៍ច្បាប់ដែលល្អបំផុត

## *គោលការណ៍ច្បាប់ដែលខុសម្តងត្រូវបណ្តេញចេញ*



- ការក្លែងបន្លំ
- ការបៀតបៀន
- ការមានការងារធ្វើ 2 កន្លែង

គឺមិនត្រូវបានអនុញ្ញាតិឲ្យមាននៅ ជោគជ័យ ឡើយ ដែលច្បាប់ធ្វើខុសម្តងបណ្តេញចេញនេះ ត្រូវបានដាក់ឲ្យអនុវត្ត។





# ក្រុមប្រឹក្សាភិបាល



**លោក Choi, Moon Kyu**
ប្រធានក្រុមប្រឹក្សាភិបាល

**ការអប់រំ**

- បរិញ្ញាបត្រជាន់ខ្ពស់ពី Thunderbird School of Global Management រដ្ឋអារីហ្សូណា សហរដ្ឋអាមេរិច
- បានបញ្ចប់ការសិក្សា ផ្នែកពាណិជ្ជកម្មពីសកលវិទ្យាល័យ Sogang ទីក្រុងសេអ៊ូល ប្រទេសកូរ៉េ

**បទពិសោធន៍ការងារ**

- បច្ចុប្បន្នជាប្រធាននាយកប្រតិបត្តិក្រុមហ៊ុន Hanshin E&C
- ធ្វើការនៅក្រុមហ៊ុន Hyundai Merchant Marine
- ធ្វើការនៅក្រុមហ៊ុន Hyundai Motor

---

**ការអប់រំ**

- បានបញ្ចប់ការសិក្សា ផ្នែកពាណិជ្ជកម្មពីសកលវិទ្យាល័យ Sogang ទីក្រុងសេអ៊ូល ប្រទេសកូរ៉េ

**បទពិសោធន៍ការងារ**

- បច្ចុប្បន្នជា នាយក នាយកដ្ឋានហិរញ្ញវត្ថុក្រុមហ៊ុន Hanshin E&C
- ធ្វើការនៅក្រុមហ៊ុន Hyundai Marine & Fire Insurance



**លោក Kim, Jung Hoon**
អភិបាលឯករាជ្យ

---



**លោក Park, Cheon Gil**
អភិបាល និង អគ្គនាយក

**ការអប់រំ**

- បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងពាណិជ្ជកម្មពីសកលវិទ្យាល័យ YONSEI (2011) ទីក្រុងសេអ៊ូល ប្រទេសកូរ៉េ
- វិញ្ញាបនបត្រ ផ្នែក Extension Marketing (2004) ពីសកលវិទ្យាល័យ UC Berkeley រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិច
- បានបញ្ចប់ការសិក្សា ផ្នែកគ្រប់គ្រងពាណិជ្ជកម្មពីសកលវិទ្យាល័យ Sogang (1998) ទីក្រុងសេអ៊ូល ប្រទេសកូរ៉េ

**បទពិសោធន៍ការងារ**

- អគ្គនាយកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រ៊ីន សិនត្រេល ប្រទេសកម្ពុជា
- នាយក នាយកដ្ឋានទីផ្សារនៃក្រុមហ៊ុន CJ Hello ទីក្រុងសេអ៊ូល ប្រទេសកូរ៉េ
- ប្រធានគ្រប់គ្រងក្រុមហ៊ុន Samsung Card ទីក្រុងសេអ៊ូល ប្រទេសកូរ៉េ
- ប្រធានក្រុមការងារនៃក្រុមហ៊ុន Hyundai Card ទីក្រុងសេអ៊ូល ប្រទេសកូរ៉េ



# គណៈគ្រប់គ្រង

ជោគជ័យ ហ្វាយនែន បើកឱកាសយ៉ាងទូលំទូលាយសម្រាប់មនុស្សគ្រប់គ្នា មិនកំណត់ចំពោះអ្នកដែលមកពីផ្នែកហិរញ្ញវត្ថុនោះទេ។ សមាជិកគណៈគ្រប់គ្រងក៏មកពីផ្នែកផ្សេងៗគ្នា ក្រៅពីផ្នែកហិរញ្ញវត្ថុផងដែរ ដូចជាពាណិជ្ជកម្ម ទូរគមនាគមន៍ កម្មវិធី software ការផលិត ការអប់រំ ក៏ដូចជាក្រុមហ៊ុនផ្នែកច្បាប់ រួមជាមួយនឹងប្រវត្តិការសិក្សាមកពីសាកលវិទ្យាល័យក្នុងស្រុក និង អន្តរជាតិ។ ការរួមផ្សំគ្នានេះបង្កើតបានជាវប្បធម៌នៃភាពជោគជ័យ ដែលជាមូលដ្ឋានគ្រឹះរឹងមាំដើម្បីរីកចម្រើនទៅមុខ។



**លោក ចេង ប៊ុនធឿន**
អគ្គនាយករង

**ការអប់រំ**

- អនុបណ្ឌិត ផ្នែករដ្ឋបាលសាធារណៈ (2016)
- បរិញ្ញាបត្រ ផ្នែកអភិវឌ្ឍសេដ្ឋកិច្ច (2007)

**បទពិសោធន៍ការងារ**

- 14 ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន មន្ត្រីគ្រប់គ្រងហានិភ័យ អនុប្រធានផ្នែកកម្ចី ប្រធានផ្នែកគ្រប់គ្រងហានិភ័យ នាយករងប្រតិបត្តិ នាយក នាយកដ្ឋានគ្រប់គ្រងហានិភ័យ ប្រធាននាយក នាយកដ្ឋានគ្រប់គ្រងហានិភ័យ និង ប្រតិបត្តិតាម និង ប្រធាននាយកប្រតិបត្តិការ

---

**ការអប់រំ**

- វិញ្ញាបនបត្រគណនេយ្យករ អ្នកបច្ចេកទេសក្រោមកម្មវិធី ACCA (2013) នៅសាលា CamEd Business School
- បរិញ្ញាបត្រ ផ្នែកអក្សរសាស្ត្រភាសាអង់គ្លេស (2015)
- បន្តការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកអនុវត្តអាជីវកម្ម នៅសាកលវិទ្យាល័យ Charles Sturt ប្រទេសអូស្ត្រាលី

**បទពិសោធន៍ការងារ**

- 6 ឆ្នាំ នៅក្នុងក្រុមហ៊ុនសវនកម្មខាងក្រៅ នៅក្នុងស្រុក និងមួយក្នុងចំនោម "Big Four" International Accounting Firm ដែលពាក់ព័ន្ធនឹងឧស្សាហកម្មផ្សេងៗ ដូចជា ស្ថាប័នហិរញ្ញវត្ថុ (ធនាគារ និង មីក្រូហិរញ្ញវត្ថុ) ពាណិជ្ជកម្ម ផលិតកម្ម និង អង្គការក្រៅរដ្ឋាភិបាល។
- ពីមុនជា នាយក នាយកដ្ឋាន ហិរញ្ញវត្ថុ ដែលជាចង្កោមនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជានារ៉ាប់រងខ្នាតតូច អាជាតមិន និង គ្លីនិក។



**លោក ខី សុទ្ធី**
ប្រធាននាយកជាន់ខ្ពស់ នាយកដ្ឋានហិរញ្ញវត្ថុ និង រតនាភិបាល

**ការអប់រំ**

- បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកច្បាប់សហប្រតិបត្តិការសេដ្ឋកិច្ចពីសាកលវិទ្យាល័យ Jean Moulin Lyon 3
- បរិញ្ញាបត្រច្បាប់ឯកជនបារាំងពីសាកលវិទ្យាល័យ Lumiere Lyon 2
- បរិញ្ញាបត្រ ផ្នែកច្បាប់កម្ពុជាពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

**បទពិសោធន៍ការងារ**

- 11 ឆ្នាំ ជាអ្នកប្រឹក្សាយោបល់ផ្នែកច្បាប់ជាមួយស្ថាប័នផ្សេងៗ រួមទាំង ក្រុមហ៊ុនច្បាប់ ធនាគារអន្តរជាតិ ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត និង គម្រោងដែលផ្តល់មូលនិធិដោយអឺរ៉ុប
- ការងារក្រៅម៉ោង៖ គ្រូឧត្តមសិក្សាវេលាកាលនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច



**កញ្ញា ផៃ ចន្ថា**
ប្រធាននាយក នាយកដ្ឋាន
នីតិកម្ម និង ប្រតិបត្តិតាម



**លោក សុខ ដាលីន**
ប្រធាននាយក នាយកដ្ឋាន
ធនធានមនុស្ស និង ទីផ្សារ

**ការអប់រំ**

- បរិញ្ញាបត្រ ផ្នែកគ្រប់គ្រងពាណិជ្ជកម្មពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា (2012)

**បទពិសោធន៍ការងារ**

- 10 ឆ្នាំក្នុងវិស័យអង្គការក្រៅរដ្ឋាភិបាល ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីទំនាក់ទំនង អ្នកសម្របសម្រួលទំនាក់ទំនងផ្នែកឌីជីថល អ្នកវិភាគពាណិជ្ជកម្ម អ្នកឯកទេសគាំទ្រ និង គ្រប់គ្រងប្រព័ន្ធ MIS ប្រធានផ្នែកវិភាគអាជីវកម្ម នាយក នាយកដ្ឋាន អភិវឌ្ឍផលិតផល និង ជានាយក នាយកដ្ឋានទីផ្សារ





**លោក ដួង សត្យា**
ប្រធាននាយក នាយកដ្ឋាន
ប្រតិបត្តិការ

**ការអប់រំ**

- បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកពាណិជ្ជកម្ម (2013)

**បទពិសោធន៍ការងារ**

- 15 ឆ្នាំ នៅក្នុងវិស័យហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន មន្ត្រីដោះស្រាយបំណុល នាយកសាខាជាន់ខ្ពស់ មន្ត្រីបណ្តុះបណ្តាល និង អភិវឌ្ឍ អនុប្រធានសាខាខេត្ត ប្រធានផ្នែកឥណទាន និង ដោះស្រាយបំណុល ប្រធានប្រចាំតំបន់ និង នាយក នាយកដ្ឋានអាជីវកម្ម

**ការអប់រំ**

- បរិញ្ញាបត្រ ផ្នែកច្បាប់ (2020)
- បរិញ្ញាបត្រ ផ្នែកអភិវឌ្ឍជនបទ (2011)

**បទពិសោធន៍ការងារ**

- 17 ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន ប្រធានក្រុមសាខា ប្រធានសាខា ប្រធានផ្នែកគ្រប់គ្រងហានិភ័យឥណទាន និង នាយក នាយកដ្ឋានគ្រប់គ្រងហានិភ័យឥណទាន



**លោក លឹម រតនៈ**
ប្រធាននាយក នាយកដ្ឋាន
គ្រប់គ្រងហានិភ័យឥណទាន



**លោក នៅ គឹមឡាយ**
ប្រធាននាយក នាយកដ្ឋានផែនការ

**ការអប់រំ**

- បរិញ្ញាបត្រ ផ្នែកធនាគារ និង ហិរញ្ញវត្ថុ (2010)
- កំពុងបន្តការសិក្សាផ្នែក ACCA នៅសាលា CamEd Business School

**បទពិសោធន៍ការងារ**

- 13 ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន មន្ត្រីជាន់ខ្ពស់ផ្នែកត្រួតពិនិត្យហិរញ្ញវត្ថុ មន្ត្រីជាន់ខ្ពស់ផ្នែករបាយការណ៍និយ័តកម្ម ប្រធានផ្នែករតនាភិបាល នាយករង នាយកដ្ឋានរតនាភិបាល នាយករង នាយកដ្ឋានផែនការ និង នាយក នាយកដ្ឋានផែនការ



**លោក ផល សិរីរតនៈ**
ប្រធាននាយក នាយកដ្ឋាន
ព័ត៌មានវិទ្យា

**ការអប់រំ**

- បរិញ្ញាបត្រ ផ្នែកព័ត៌មានវិទ្យា និង វិទ្យាសាស្ត្រកុំព្យូទ័រ

**បទពិសោធន៍ការងារ**

- 5 ឆ្នាំ លើក្រុមហ៊ុនទូរគមនាគមន៍
- ធ្លាប់កាន់តំណែងជា អ្នកបង្កើតកម្មវិធី អ្នកអភិវឌ្ឍកម្មវិធីជាន់ខ្ពស់ ប្រធានផ្នែក Billing និង ប្រធានផ្នែកព័ត៌មានវិទ្យា

**ការអប់រំ**

- បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកធនាគារ និង ហិរញ្ញវត្ថុ (2016)

**បទពិសោធន៍ការងារ**

- 11 ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ (ជោគជ័យ និង អម្រឹត)
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន មន្ត្រីឥណទានជាន់ខ្ពស់ មន្ត្រីសវនកម្មផ្ទៃក្នុង មន្ត្រីសវនកម្មផ្ទៃក្នុងជាន់ខ្ពស់ ប្រធានសវនកម្មផ្ទៃក្នុង និង នាយក នាយកដ្ឋានសវនកម្មផ្ទៃក្នុង



**លោក អ៊ុន សេងទ្រឿ**
ប្រធាននាយក នាយកដ្ឋាន
សវនកម្មផ្ទៃក្នុង





**លោក ឈូ សុខលាភ**
នាយករង នាយកដ្ឋានដោះស្រាយបំណុល

**ការអប់រំ**

- បរិញ្ញាបត្រ ផ្នែកធនាគារ និង ហិរញ្ញវត្ថុ

**បទពិសោធន៍ការងារ**

- 14 ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ (ប្រ៊ីដ វេលខម ហ្វាយនែន និង ជោគជ័យ)
- ធ្លាប់កាន់តំណែងជា មន្ត្រីទំនាក់ទំនងអតិថិជន មន្ត្រីឥណទាន ប្រធានមន្ត្រីឥណទាន ប្រធានសាខា និង ប្រធានផ្នែកសវនកម្មផ្ទៃក្នុង

**ការអប់រំ**

- បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកពាណិជ្ជកម្ម (2019)

**បទពិសោធន៍ការងារ**

- 10 ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន ប្រធានមន្ត្រីឥណទាន នាយកសាខា និង ប្រធានផ្នែកគ្រប់គ្រងតំបន់



**លោក វ៉េត ហ៊ង**
នាយករង នាយកដ្ឋានប្រតិបត្តិការ



**លោក ភឿក ភត្រា**
នាយករង នាយកដ្ឋាន
គ្រប់គ្រងហានិភ័យឥណទាន

**ការអប់រំ**

- បរិញ្ញាបត្រ ផ្នែកគ្រប់គ្រងអាជីវកម្ម (2014)

**បទពិសោធន៍ការងារ**

- 11 ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន សវនករផ្ទៃក្នុង សវនករអភិវឌ្ឍ និង របាយការណ៍សវនកម្ម សវនករផ្ទៃក្នុងជាន់ខ្ពស់ ប្រធានផ្នែកសវនកម្មផ្ទៃក្នុង ប្រធានផ្នែកសវនកម្មប្រតិបត្តិការ នាយករង នាយកដ្ឋានសវនកម្មផ្ទៃក្នុង និង ប្រធានផ្នែកគាំទ្រសាខា



**លោក ទិន ម៉ូសត្យា**
នាយករង នាយកដ្ឋាន
អភិវឌ្ឍផលិតផល

**ការអប់រំ**

- បរិញ្ញាបត្រ ផ្នែកគ្រប់គ្រងសហគ្រាស ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច (2011)

**បទពិសោធន៍ការងារ**

- 12 ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីគ្រប់គ្រងឥណទាន ប្រធានក្រុមអភិវឌ្ឍផលិតផល និង ប្រធានផ្នែកអភិវឌ្ឍផលិតផល



**លោក រិន សុផារ៉ា**
នាយករង នាយកដ្ឋាន
ត្រួតពិនិត្យផលបត្រឥណទាន

**ការអប់រំ**

- បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងធនធានមនុស្ស (2019)

**បទពិសោធន៍ការងារ**

- 9 ឆ្នាំ ក្នុងវិស័យអប់រំ
- 2 ឆ្នាំ ជាប្រធានផ្នែកធនធានមនុស្ស និង 2 ឆ្នាំ ជាប្រធានផ្នែកត្រួតពិនិត្យផលបត្រឥណទាន

---

**ការអប់រំ**

- បរិញ្ញាបត្រ ផ្នែកធនាគារ និង ហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យន័រតុន (2016)

**បទពិសោធន៍ការងារ**

- 7 ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីសន្សំ សវនករប្រចាំតំបន់ សវនករប្រចាំតំបន់ជាន់ខ្ពស់ សវនករប្រតិបត្តិការជាន់ខ្ពស់ និង ប្រធានផ្នែកសវនកម្មផ្ទៃក្នុង



**លោក ផាត់ ឃ្មិ**
នាយករង នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**ការអប់រំ**

- បរិញ្ញាបត្រ ផ្នែកអក្សរសាស្ត្រអង់គ្លេស (2017)

**បទពិសោធន៍ការងារ**

- 5 ឆ្នាំ ក្នុងវិស័យអប់រំ នៅសាលាអន្តរជាតិ
- ចាប់ផ្តើមការងារក្នុងវិស័យមីក្រូហិរញ្ញវត្ថុ តាំងពី ខែមករា ឆ្នាំ 2020 ពីអ្នកបកប្រែ ប្រធានផ្នែកអាជីវកម្មឌីជីថល និង ប្រធានផ្នែកផែនការឥណទាន



**កញ្ញា សំណាង សុមាស**
នាយករង នាយកដ្ឋានផែនការឥណទាន
និង ជំនួយការអគ្គនាយករង

# ទិដ្ឋភាពទូទៅនៃអាជីវកម្ម


ដៃគូផ្ដល់ទុនវិនិយោគ ........ 36
ដៃគូអាជីវកម្ម ........ 36
សមាជិកភាព ........ 36
ការបង្ហាញទិន្នន័យគ្រួសៗ ........ 37
ផលិតផលឥណទាន ........ 39
សាខាប្រតិបត្តិការ ........ 40
ប្រវត្តិជោគជ័យរបស់អតិថិជន ........ 41


## ដៃគូផ្ដល់ទុនវិនិយោគ

KB Kookmin Bank
Industrial Bank of Korea
PPCBank
KDB Bank
KDSB
Shinhan Bank

## ដៃគូអាជីវកម្ម

Wing
true money
FORTE INSURANCE
HYUNDAI
CAMKO MOTOR COMPANY LTD

## យើងមានក្ដីរីករាយដែលជាសមាជិកនៃ

EUROCHAM CAMBODIA
AMCHAM CAMBODIA
KOCHAM
Cambodia Microfinance Association
IBC
BNI

# ការបង្ហាញទិន្នន័យគ្រួស។

(គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ2022)

## សមតុល្យផលបត្រឥណទាន

**52,0**

លានដុល្លារ




## មូលនិធិផ្ទាល់សុទ្ធ

**10,7**

លានដុល្លារ

## ដើមទុនចុះបញ្ជី

**5,5**

លានដុល្លារ




## ផលលើទ្រព្យសកម្ម

**2.5%**




## ផលលើមូលធន

**16.3%**



# ផលិតផលឥណទាន

## ឥណទានទូទៅ

| | |
|---|---|
| ទំហំកម្ចី | រហូតដល់ $30,000 |
| រយៈពេលកម្ចី | រហូតដល់ 72 ខែ |

## ឥណទានយានយន្ត

| | |
|---|---|
| ទំហំកម្ចី | រហូតដល់ $100,000 |
| រយៈពេលកម្ចី | រហូតដល់ 84 ខែ |

## ឥណទានកសិកម្ម

| | |
|---|---|
| ទំហំកម្ចី | រហូតដល់ $30,000 |
| រយៈពេលកម្ចី | រហូតដល់ 72 ខែ |

## ឥណទានអាជីវកម្ម

| | |
|---|---|
| ទំហំកម្ចី | រហូតដល់ $150,000 |
| រយៈពេលកម្ចី | រហូតដល់ 120 ខែ |

## ឥណទានកាតគ្រីយានយន្ត

| | |
|---|---|
| ទំហំកម្ចី | រហូតដល់ $30,000 |
| រយៈពេលកម្ចី | រហូតដល់ 60 ខែ |

## ឥណទានទាន់ចិត្ត

| | |
|---|---|
| ទំហំកម្ចី | រហូតដល់ $10,000 |
| រយៈពេលកម្ចី | រហូតដល់ 60 ខែ |

## ឥណទានអេឡិចត្រូនិច

| | |
|---|---|
| ទំហំកម្ចី | រហូតដល់ $1,000 |
| រយៈពេលកម្ចី | រហូតដល់ 24 ខែ |

## ឥណទានសង្គ្រោះបន្ទាន់

| | |
|---|---|
| ទំហំកម្ចី | រហូតដល់ $5,000 |
| រយៈពេលកម្ចី | រហូតដល់ 24 ខែ |

## ឥណទានក្រុមធានា

| | |
|---|---|
| ទំហំកម្ចី | រហូតដល់ 8,000,000 រៀល/ម្នាក់ |
| រយៈពេលកម្ចី | រហូតដល់ 36 ខែ |



# សាខាប្រតិបត្តិការ




**07** ខេត្ត / ក្រុង ប្រតិបត្តិការ

**11** សាខា ប្រតិបត្តិការ

**រាជធានីភ្នំពេញ**

1. ការិយាល័យកណ្តាល
2. សាខាសែនសុខ

**ខេត្តកណ្តាល**

3. សាខាក្រុងតាខ្មៅ

**ខេត្តកំពង់ស្ពឺ**

4. សាខាថ្នល់ទទឹង
5. សាខាកំពង់ស្ពឺ
6. សាខាគងពិសី

**ខេត្តកំពង់ឆ្នាំង**

7. សាខាកំពង់ត្រឡាច

**ខេត្តកំពត**

11. សាខាឈូក

**ខេត្តកំពង់ចាម**

8. សាខាជើងព្រៃ
9. សាខាស្រីសន្ធរ

**ខេត្តតាកែវ**

10. សាខាត្រាំកក់

# ប្រវត្តិជោគជ័យរបស់អតិថិជន



លោកស្រី សុភាព បាននិយាយដោយទឹកមុខញញឹមថា " ខ្ញុំពិតជាមានក្តីរីករាយជាមួយនឹងអ្វីដែលខ្ញុំកំពុងតែមានបច្ចុប្បន្ននេះ។ មុខរបររបស់ខ្ញុំទាំងអស់បានផ្តល់នូវចំណូលច្រើនដល់ខ្ញុំ។ ជោគជ័យ ពិតជាបាននាំនៅសំណាងល្អដល់ខ្ញុំដូចឈ្មោះស្ថាប័ន ដែលមានឈ្មោះថា ជោគជ័យមែន។ "

លោកស្រី ហៃល សុភាព មានអាយុ 50 ឆ្នាំ ហើយគាត់រស់នៅក្នុង ភូមិរំលេច ឃុំរលាំងគ្រើល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ គាត់បានចាប់ផ្តើមសន្ទនាជាមួយពួកយើងនៅខាងមុខផ្ទះរបស់គាត់ ដោយទឹកមុខញញឹមរីករាយ បើទោះបីជាគាត់ចាប់ផ្តើមចែករំលែកអំពីទុក្ខលំបាករបស់គាត់ ដែលគាត់បានជួបកន្លងមកក៏ដោយ។គាត់បានលើកឡើងថាគាត់ពីមុនជាអ្នកលក់សាច់គោម្នាក់នៅក្នុងផ្សារ ហើយគាត់មិនអាចរកចំណូលបានគ្រប់គ្រាន់ ដើម្បីផ្គត់ផ្គង់ក្រុមគ្រួសារ ដែលមានសមាជិកច្រើនរបស់គាត់បានឡើយ។ ប្រាក់ចំណេញដែលគាត់រកបាន គឺទាបដោយសារតែគាត់យកសាច់គេពីគេមកលក់បន្ត។ ជារៀងរាល់ថ្ងៃ គាត់នៅតែបន្តមុខរបររបស់គាត់បែបនេះ ហើយគាត់មិនមានភាពរីកចម្រើនណាមួយឡើយ។

ក្រោយមកគាត់បានស្គាល់ ជោគជ័យ ហើយបានស្នើសុំឥណទាន អេស អឹម អ៊ី។ អ្វីៗគ្រប់យ៉ាងបានចាប់ផ្តើមប្រសើរឡើងគួរឲ្យកត់សម្គាល់ បន្ទាប់ពីគាត់ទទួលបានដើមទុនបន្ថែម ដែលពេលនោះគាត់បានក្លាយជាអ្នកបោះដុំសាច់គោ បើកលក់ឥវ៉ាន់ចាប់ហួយ ក៏ដូចជា បើកហាងលក់ម្ហូបអាហារតូចមួយនៅផ្ទះរបស់គាត់ផងដែរ។ ដោយមានមុខរបប៉ុន្មានមុខនេះ គាត់មានលទ្ធភាពទិញរថយន្តមួយ និង ដីមួយកន្លែងដើម្បីសាងសង់បន្ទប់ជួល សម្រាប់កម្មកររោងចក្រនៅថ្ងៃខាងមុខ ដែលនៅពេលនោះ គាត់នឹងទទួលបានចំណូលកាន់តែច្រើនបន្ថែមទៀត។





ភរិយាលោក សារ៉ាត់ បាននិយាយថា " ខ្ញុំរីករាយណាស់ ដែលគ្រួសាររបស់ខ្ញុំមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ចាប់តាំងពីពេលដែលខ្ញុំទទួលបានឥណទានពី ជោគជ័យ។ ខ្ញុំអាចលក់ដូរបណ្តើរ និង មើលថែទាំកូនៗរបស់ខ្ញុំបណ្តើរ។ នេះគឺជាអ្វីដែលខ្ញុំតែងតែរំពឹងទុកកន្លងមក។ "

លោក សារ៉ាត់ មានអាយុ 37 ឆ្នាំ ហើយគាត់រស់នៅភូមិរការធំ ឃុំរការធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។ គាត់ពីដើមឡើយគឺជាកម្មករសំណង់ ហើយចំណែកឯប្រពន្ធរបស់គាត់គឺជាអតីតកម្មកររោងចក្រមុនពេលពេលដែលពួកគាត់ទាំងពីរបានស្គាល់ ជោគជ័យ។ ពួកគាត់ពិតជាមានការលំបាកខ្លាំង ក្នុងការទំនុកបម្រុងក្រុមគ្រួសារ ដោយពួកគាត់រកចំណូលបានតិចតួចបើទោះជាបូកបញ្ចូលគ្នាក៏ដោយ។

គ្រប់យ៉ាងបានផ្លាស់ប្តូរ នៅពេលដែលពួកគាត់បានស្នើរឥណទាន ទាន់ចិត្ត ពីជោគជ័យ។ លោកសារ៉ាត់បានផ្លាស់ប្តូរទៅជាអ្នកម៉ៅការសំណង់ នៅក្នុងតំបន់របស់គាត់ ក៏ដូចជាគម្រោងម៉ៅការសំណង់នានាដែលមាន។ ប្រពន្ធរបស់គាត់ក៏ឈប់ធ្វើការនៅរោងចក្រទៀតដែរ ដោយគាត់បានបើកលក់ឥវ៉ាន់ចាប់ហួយនៅមុខសំយ៉ាបមុខផ្ទះរបស់គាត់ ដែលគាត់ព្រមទាំងមានពេលមើលថែកូនៗរបស់គាត់ផងដែរ។

ការរីកចម្រើនជាបន្តបន្ទាប់នេះ ក៏បានធ្វើឲ្យលោក សារ៉ាត់ និង ភរិយារបស់គាត់មានលទ្ធភាពទិញដីមួយកន្លែង ពង្រីកកន្លែងលក់ចាប់ហួយ និង មានទំនិញបន្ថែមទៀត សម្រាប់លក់ទៅឲ្យអ្នកទិញផងដែរ។



# របាយការណ៍ហិរញ្ញវត្ថុ


របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ........ 44
របាយការណ៍របស់សវនករឯករាជ្យ ........ 49
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ........ 52
របាយការណ៍លទ្ធផលលម្អិត ........ 54
របាយការណ៍ស្តីពីបម្រែបម្រួលមូលធន ........ 55
របាយការណ៍លំហូរសាច់ប្រាក់ ........ 57


# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានសេចក្តីសោមនស្សរីករាយក្នុងការដាក់ជូននូវរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនដោយភ្ជាប់ជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ ជោគជ័យ ហ្វាយនែន ភីអិលស៊ី ហៅកាត់ថា (ក្រុមហ៊ុន) ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022។

## សកម្មភាពអាជីវកម្មចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺផ្តល់ជូននូវសេវាហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពដល់សហគ្រិនធុនតូច និង មធ្យម និង គ្រួសារដែលមានប្រាក់ចំណូលទាបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ពុំមានការប្រែប្រួលជាសារវន្តទៅលើសកម្មភាពចម្បងនៅក្នុងការិយបរិច្ឆេទនេះទេ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានដូចខាងក្រោម៖

| | 2022 | | 2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) |
| ប្រាក់ចំណេញមុនដកពន្ធ | 1,758,717 | 7,187,877 | 1,217,747 | 4,953,796 |
| ចំណាយពន្ធលើប្រាក់ចំណេញ | (395,507) | (1,616,437) | (264,242) | (1,074,936) |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | 1,363,210 | 5,571,440 | 953,505 | 3,878,860 |

## ភាគលាភ

ពុំមានភាគលាភណាត្រូវបានប្រកាស ឬត្រូវបានបង់ ហើយក្រុមប្រឹក្សាភិបាលក៏ពុំបានផ្តល់ជាអនុសាសន៍ឱ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទនេះទេ។

## ដើមទុន

ដើមទុនដែលបានបង់របស់ក្រុមហ៊ុននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022 មានចំនួន 5,500,000 ដុល្លារអាមេរិក (2021: 5,500,000) ដុល្លារអាមេរិក ដែលក្នុងនោះមួយភាគហ៊ុនមានតម្លៃស្មើនឹង 10 ដុល្លារអាមេរិក។ ភាគហ៊ុន និង

របនាសម្ព័ន្ធ របស់ក្រុមហ៊ុនលម្អិតត្រូវបានលាតត្រដាងនៅកំណត់សម្គាល់ 11។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុង របាយការណ៍ហិរញ្ញវត្ថុនេះ។

## ឥណទានអាក្រក់ និងឥណទានជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថាវិធានការទាក់ទង នឹងការលុបចោលនូវឥណទានអាក្រក់ និង ការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយមានការជឿជាក់ថាមិនមានឥណទានអាក្រក់ និងសំវិធានធនត្រូវបានធ្វើឡើងសម្រាប់ឥណទានជាប់សង្ស័យ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានពិនិត្យឃើញមានស្ថានភាពណាមួយដែលអាចនឹងបណ្តាលឱ្យចំនួននៃការលុបបំបាត់ចោល ឥណទានអាក្រក់ ឬចំនួននៃការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះមានចំនួនខ្វះខាតជាសារវន្តនោះឡើយ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្តទាំងអស់ ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យ របស់ក្រុមហ៊ុន ហើយដែលទំនងជាមិនអាចលក់បាននៅក្នុងប្រតិបត្តិការ អាជីវកម្មធម្មតាត្រូវបានកាត់បន្ថយឱ្យនៅស្មើនឹងតម្លៃដែលរំពឹងទុកថានឹងអាចប្រមូលបានជាក់ស្តែង។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងធ្វើឱ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវនោះទេ។

## វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើងដែលនឹងធ្វើឱ្យប៉ះពាល់ដល់ វិធីសាស្ត្រកំណត់តម្លៃដែលបានអនុវត្តកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និង បំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

## បំណុលយថាភាព

នាថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះពុំមាន៖

(ក) ការប្រែប្រួលទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលកើតមានឡើងដោយសារការដាក់បញ្ចាំ សម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាមួយ ចាប់តាំងពីដំណាច់ឆ្នាំឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលមានមតិថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុនដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងរយៈពេល 12 ខែបន្ទាប់ពីចុងការិយបរិច្ឆេទនេះ ដែលនឹងធ្វើឱ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចដែលបានកំណត់និងនៅពេលដែលដល់ថ្ងៃកំណត់។



## ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឱ្យមានតួលេខនៃចំនួនណាមួយ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាលមានមតិថា លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមិនមានផលប៉ះពាល់ជាសារវន្ត ដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទ ដល់ថ្ងៃចេញរបាយការណ៍នេះពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និង មិនប្រក្រតីកើតមានឡើងដែលអាចនាំឱ្យប៉ះពាល់ដល់លទ្ធផល នៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទ ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

ពុំមានព្រឹត្តិការណ៍សារវន្តកើតឡើង ក្រោយកាលបរិច្ឆេទរាយការណ៍ ដែលតម្រូវឱ្យមានការលាតត្រដាង ឬនិយ័តភាពក្រៅពីព្រឹត្តិការណ៍ដែលបានលាតត្រដាងរួចហើយ នៅក្នុងកំណត់សម្គាល់ដែលភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ។

## សមាជិកក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល ដែលបម្រើការនៅក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះមានរាយនាមដូចខាងក្រោម៖

- លោក Moon Kyu Choi
  ប្រធានក្រុមប្រឹក្សាភិបាល
- លោក Cheon Gil Park
  អភិបាល និង នាយកប្រតិបត្តិ
- លោក Jung Hoon Kim
  អភិបាលឯករាជ្យ

## ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ 11 នៃរបាយការណ៍ហិរញ្ញវត្ថុ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

មិនថានៅចុងការិយបរិច្ឆេទ ឬនៅក្នុងអំឡុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ គឺមិនមានកិច្ចព្រមព្រៀងណាមួយដែលក្រុមហ៊ុនជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះ អាចផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាលណាម្នាក់ ឱ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗដូចជា ការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬសាជីវកម្មដទៃ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនៃឆ្នាំកន្លងទៅ ក្រុមប្រឹក្សាភិបាលពុំបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ( ក្រៅពីអត្ថប្រយោជន៍ដែលបានរាប់បញ្ចូល ក្នុងចំនួនសរុបនៃលាភការដែលបានទទួល ឬកំណត់នឹងអាចទទួលបានដោយក្រុមប្រឹក្សាភិបាល ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុនជាមួយក្រុមប្រឹក្សាភិបាល ឬដោយក្រុមហ៊ុនផ្សេងដែលមានក្រុមប្រឹក្សាភិបាលជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនផ្សេងដែលមានក្រុមប្រឹក្សាភិបាលជាសមាជិកនោះ មានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ច្រើនជាងអ្វីត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានភារៈធ្វើការអះអាងបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុ បានរៀបចំឡើងយ៉ាងត្រឹមត្រូវក្នុងកម្រិតជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022 និង ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (“CIFRS for SMEs”)។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះក្រុមប្រឹក្សាភិបាលត្រូវ៖

ក) អនុម័តនូវគោលនយោបាយគណនេយ្យ សមស្របដោយផ្អែកលើការវិនិច្ឆ័យ និង ការប៉ាន់ប្រមាណយ៉ាងសមហេតុផល និង ប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាម គោលនយោបាយទាំងនេះប្រកបដោយសង្គតិភាព។

ខ) អនុលោមទៅតាម CIFRS for SMEs ឬ ប្រសិនបើមានការប្រាសចាកពីនេះដើម្បីបង្ហាញពីភាពពិត និងត្រឹមត្រូវ គឺត្រូវតែបង្ហាញ និង ពន្យល់ឱ្យបានច្បាស់លាស់ និង កំណត់ចំនួននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការ រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងការរក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព។

ឃ) វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុន ចំពោះការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយ ដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និង ប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃស្តង់ដារគណនេយ្យ លើកលែងតែក្រុមប្រឹក្សាភិបាល មានបំណងចង់ជម្រះបញ្ជីក្រុមហ៊ុន ឬ បញ្ឈប់ប្រតិបត្តិការ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

ង) ត្រួតពិនិត្យ និង ដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចសំខាន់ៗទាំងឡាយ ដែលប៉ះពាល់ដល់ សកម្មភាពប្រតិបត្តិការ និង ដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាង ត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តនូវរាល់តម្រូវការដូចដែលបានរាយការណ៍ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលសូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដែលភ្ជាប់មកជាមួយដូចបានបង្ហាញនៅទំព័រទី 10 ដល់ 52 ថាបានបង្ហាញនូវភាពត្រឹមត្រូវក្នុងកម្រិតជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2022 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និង លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម។

ចុះហត្ថលេខាដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

លោក Cheon Gil Park
អភិបាល និង នាយកប្រតិបត្តិ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី24 ខែមេសា ឆ្នាំ2023

# របាយការណ៍របស់សវនករឯករាជ្យ

**ជូនចំពោះភាគទុនិក**
**ជោគជ័យ ហ្វាយនែន ភីអិលស៊ី**

## មតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្ម លើរបាយការណ៍ហិរញ្ញវត្ថុ របស់ ជោគជ័យ ហ្វាយនែន ភីអិលស៊ី ហៅកាត់ (ក្រុមហ៊ុន) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022 របាយការណ៍លទ្ធផលលម្អិត របាយការណ៍ស្ដីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗទៀតដែលបានបង្ហាញនៅទំព័រទី 10 ដល់ 52។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវភាពត្រឹមត្រូវក្នុងកម្រិតជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ ក្រុមហ៊ុននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (“CIFRS for SMEs”)។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំ ដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀត នៅក្នុងកថាខណ្ឌស្តីពីការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានឯករាជ្យភាពពីក្រុមហ៊ុន តាមតម្រូវការនៃក្រមសីលធម៌ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម លើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញតាមក្របខណ្ឌ ទំនួលខុសត្រូវក្រមសីលធម៌ផ្សេងៗស្របតាមតម្រូវការទាំងនោះ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែល យើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

## បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2021 ត្រូវបានធ្វើសវនកម្ម ដោយសវនករផ្សេងទៀតដែលបានបញ្ចេញមតិសវនកម្មនៅថ្ងៃទី 30 ខែ មេសា ឆ្នាំ 2022។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រង មានការទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ ដែលបានទទួលត្រឹមកាលបរិច្ឆេទ នៃរបាយការណ៍របស់សវនករ មានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលនៅទំព័រ 1 ដល់ទី 5 ចំណែកឯរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន រំពឹងថានឹងផ្តល់ឱ្យយើងខ្ញុំ ក្រោយកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ។

មតិរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុមិនបានគ្របដណ្តប់ព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំក៏មិនបានផ្តល់នូវ អំណះអំណាងណាមួយ លើព័ត៌មានផ្សេងៗទាំងនេះឡើយ។ ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះមានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្តឬទេ។

ប្រសិនបើការមានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឱ្យយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តកើតឡើង យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវ រាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវ លើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវ នៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ហើយនឹងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំ របាយការណ៍ហិរញ្ញវត្ថុឱ្យជៀសផុត ពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវ លើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយ ដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យ ដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូល មិនមានការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផលគឺជា អំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថាគ្រប់ពេលនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្ត ដែលបានកើតឡើងនោះទេ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នាមានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមន្ទិលជាគុនិយម ក្នុងអំឡុងពេលសវនកម្ម។ យើងខ្ញុំក៏បាន៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្ត លើរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការ ក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹង ហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការ បញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្ត ដែលកើតឡើងដោយសារតែការក្លែងបន្លំមាន លក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើង ពីកំហុសឆ្គងដោយសារតែការក្លែងបន្លំ អាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនាការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។
- ទទួលបាននូវការយល់ដឹង អំពីការគ្រប់គ្រងផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធី សវនកម្មដែលសម

ស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញ មតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។

- ការវាយតម្លៃលើភាព សមស្របនៃគោលនយោបាយគណនេយ្យ ដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផល នៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មាន ពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។
- ធ្វើការសន្និដ្ឋាន លើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃ គណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់ជាសារវន្ត ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឱ្យមានមន្ទិលជាសារវន្តលើ លទ្ធភាពរបស់ក្រុមហ៊ុនដើម្បីបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំធ្វើការសន្និដ្ឋានថាមានអត្ថិភាព នៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍ លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបាន ត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ យ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឱ្យបញ្ឈប់នូវនិរន្តរភាពនៃអាជីវកម្ម។
- វាយតម្លៃលើការបង្ហាញ រចនាសម្ព័ន្ធ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថា តើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យ ដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំបានផ្តល់ព័ត៌មានជូន អ្នកទទួលខុសត្រូវលើអភិបាលកិច្ចចំពោះកត្តាពាក់ព័ន្ធនឹងសវនកម្មរួមមានជាអាទិ៍វិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាសវនកម្មជាសារវន្ត រួមបញ្ចូលទាំងចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបាន រកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន **អេហ្វអាយអាយ & អឹសូស៊ីអេត**



**សេង ចាន់ថន**
ដៃគូសវនករ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី24 ខែមេសា ឆ្នាំ2023



# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

## នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022

| | 2022 | | 2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) |
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ក្នុងដៃ | 86,007 | 354,091 | 73,577 | 299,753 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា | 277,675 | 1,143,188 | 277,552 | 1,130,747 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ | 2,288,442 | 9,421,516 | 698,694 | 2,846,479 |
| ឥណទានផ្តល់ដល់អតិថិជន | 52,022,303 | 214,175,821 | 43,078,426 | 175,501,508 |
| ទ្រព្យសកម្មផ្សេងៗ | 168,331 | 693,019 | 179,802 | 732,513 |
| ទ្រព្យ និងបរិក្ខារ | 433,087 | 1,783,019 | 419,629 | 1,709,569 |
| ទ្រព្យសកម្មអរូបី | 189,851 | 781,617 | 216,845 | 883,427 |
| **ទ្រព្យសកម្មសរុប** | **55,465,696** | **228,352,271** | **44,944,525** | **183,103,996** |
| **មូលធន និងបំណុល** | | | | |
| **បំណុល** | | | | |
| បំណុលផ្សេងៗ | 668,934 | 2,754,002 | 485,490 | 1,977,886 |
| ប្រាក់កម្ចីរយៈពេលខ្លី | 24,616,420 | 101,345,801 | 15,726,815 | 64,071,044 |
| ប្រាក់កម្ចីរយៈពេលវែង | 21,487,612 | 88,464,499 | 21,519,146 | 87,669,001 |
| ពន្ធពន្យារជាបំណុល-សុទ្ធ | 29,586 | 121,806 | - | - |
| បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | 293,594 | 1,208,726 | 206,734 | 842,234 |
| **បំណុលសរុប** | **47,096,146** | **193,894,834** | **37,938,185** | **154,560,165** |

| | 2022 | | 2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) |
| មូលធន | | | | |
| ដើមទុន | 5,500,000 | 22,199,000 | 5,500,000 | 22,199,000 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 767,320 | 3,147,611 | 487,464 | 1,974,481 |
| ប្រាក់ចំណេញរក្សាទុក | 2,102,230 | 8,557,942 | 1,018,876 | 4,159,632 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 552,884 | - | 210,718 |
| មូលធនសរុប | 8,369,550 | 34,457,437 | 7,006,340 | 28,543,831 |
| **មូលធន និងបំណុលសរុប** | **55,465,696** | **228,352,271** | **44,944,525** | **183,103,996** |

# របាយការណ៍លទ្ធផលលម្អិត

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022

| | 2022 | | 2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) |
| ចំណូលពីការប្រាក់ | 7,777,724 | 31,787,558 | 6,165,862 | 25,082,727 |
| ចំណាយលើការប្រាក់ | (2,278,947) | (9,314,056) | (1,773,305) | (7,213,805) |
| **ចំណូលពីការប្រាក់សរុប** | **5,498,777** | **22,473,502** | **4,392,557** | **17,868,922** |
| | | | | |
| ចំណូលប្រតិបត្តិការផ្សេងៗ | 135,735 | 554,749 | 88,879 | 361,560 |
| ចំណាយទូទៅ និងរដ្ឋបាល | (3,652,631) | (14,928,303) | (3,250,580) | (13,223,359) |
| ការខាតបង់លើឱនភាពនៃឥណទានផ្តល់ដល់អតិថិជន | (223,164) | (912,071) | (13,109) | (53,327) |
| **ប្រាក់ចំណេញមុនដកពន្ធ** | **1,758,717** | **7,187,877** | **1,217,747** | **4,953,796** |
| | | | | |
| ចំណាយពន្ធលើប្រាក់ចំណេញ | (395,507) | (1,616,437) | (264,242) | (1,074,936) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | **1,363,210** | **5,571,440** | **953,505** | **3,878,860** |
| | | | | |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 342,166 | - | 135,253 |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | **1,363,210** | **5,913,606** | **953,505** | **4,014,113** |

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022

| | ដើមទុន | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ប្រាក់ខាតបង្គរ | | លម្អៀងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) |
| នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2021 | 3,500,000 | 14,063,000 | 249,734 | 1,007,395 | 303,101 | 1,247,858 | - | 75,465 | 4,052,835 | 16,393,718 |
| ដើមទុនបន្ថែម | 2,000,000 | 8,136,000 | - | - | - | - | - | - | 2,000,000 | 8,136,000 |
| **លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | 953,505 | 3,878,860 | - | - | 953,505 | 3,878,860 |
| ការផ្ទេរ | - | - | 237,730 | 967,086 | (237,730) | (967,086) | - | - | - | - |
| ***លទ្ធផលលម្អិតផ្សេងៗ*** | | | | | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | 135,253 | - | 135,253 |
| **សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | - | - | 237,730 | 967,086 | 715,775 | 2,911,774 | - | 135,253 | 953,505 | 4,014,113 |
| **នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2021** | **5,500,000** | **22,199,000** | **487,464** | **1,974,481** | **1,018,876** | **4,159,632** | **-** | **210,718** | **7,006,340** | **28,543,831** |
| នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2022 | 5,500,000 | 22,199,000 | 487,464 | 1,974,481 | 1,018,876 | 4,159,632 | - | 210,718 | 7,006,340 | 28,543,831 |
| **លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | 1,363,210 | 5,571,440 | - | - | 1,363,210 | 5,571,440 |
| ការផ្ទេរ | - | - | 279,856 | 1,173,130 | (279,856) | (1,173,130) | - | - | - | - |
| ***លទ្ធផលលម្អិតផ្សេងៗ*** | | | | | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | 342,166 | - | 342,166 |
| **សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | - | - | 279,856 | 1,173,130 | 1,083,354 | 4,398,310 | - | 342,166 | 1,363,210 | 5,913,606 |
| **នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022** | **5,500,000** | **22,199,000** | **767,320** | **3,147,611** | **2,102,230** | **8,557,942** | **-** | **552,884** | **8,369,550** | **34,457,437** |

# របាយការណ៍លំហូរសាច់ប្រាក់

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022

| | 2022 | | 2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) |
| **លំហូរសាច់ប្រាក់ពីសកម្មប្រតិបត្តិការ** | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | 1,363,210 | 5,571,440 | 953,505 | 3,878,860 |
| *និយ័តកម្មលើ៖* | | | | |
| រំលស់ទ្រព្យ និងបរិក្ខារ | 163,577 | 668,539 | 159,106 | 647,243 |
| រំលស់ទ្រព្យសកម្មអរូបី | 26,994 | 110,324 | 27,016 | 109,901 |
| ការខាតបង់លើឱនភាពនៃឥណទានផ្តល់ដល់អតិថិជន | 223,164 | 912,071 | 13,109 | 53,327 |
| ទ្រព្យ និងបរិក្ខារដែលលុបចោល | 83 | 339 | 335 | 1,363 |
| **ចំណាយពន្ធលើប្រាក់ចំណេញ** | 395,507 | 1,616,437 | 264,242 | 1,074,936 |
| | 2,172,535 | 8,879,150 | 1,417,313 | 5,765,630 |
| *បម្រែបម្រួលនៃ៖* | | | | |
| ប្រាក់តម្កល់ធានាលើដើមទុន | - | - | (100,000) | (406,800) |
| ឥណទានផ្តល់ដល់អតិថិជន | (9,167,041) | (37,465,697) | (11,865,045) | (48,267,003) |
| ទ្រព្យសកម្មផ្សេងៗ | 11,471 | 46,882 | (66,111) | (268,940) |
| បំណុលផ្សេងៗ | 183,444 | 749,736 | 201,564 | 819,962 |
| សាច់ប្រាក់ប្រើប្រាស់ក្នុងប្រតិបត្តិការ | (6,799,591) | (27,789,929) | (10,412,279) | (42,357,151) |

| | 2022 | | 2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) |
| ពន្ធលើប្រាក់ចំណេញដែលបានបង់ | (279,061) | (1,140,522) | (88,020) | (358,065) |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ | (7,078,652) | (28,930,451) | (10,500,299) | (42,715,216) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | (177,118) | (723,881) | (162,916) | (662,742) |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ | (177,118) | (723,881) | (162,916) | (662,742) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | 8,858,071 | 36,202,936 | 8,919,146 | 36,283,086 |
| ដើមទុនបន្ថែម | - | - | 1,100,000 | 4,474,800 |
| សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន | 8,858,071 | 36,202,936 | 10,019,146 | 40,757,886 |
| **ការកើនឡើង /(ថយចុះ)សុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | 1,602,301 | 6,548,604 | (644,069) | (2,620,072) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី1 ខែមករា | 774,823 | 3,156,629 | 1,418,892 | 5,772,053 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 81,387 | - | 4,648 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី 31 ខែ ធ្នូ (កំណត់សម្គាល់ 19) | 2,377,124 | 9,786,620 | 774,823 | 3,156,629 |

# ការិយាល័យកណ្តាល

ផ្ទះលេខ 9 -11 ផ្លូវវេងស្រេង ភូមិដំណាក់ធំ 5
សង្កាត់ស្ទឹងមានជ័យទី 3 ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខ : 023 922 126
ហ្វេសបុក : ChokChey Finance Plc
អ៊ីម៉ែល : info@chokchey.com.kh
គេហទំព័រ : www.chokchey.com.kh